# សេចក្តីថ្លែងការណ៍រួម

## សូមទម្លាក់ចោលបទចោទទាំងអស់ចំពោះសកម្មជនមាតាធម្មជាតិ និងដោះលែង អ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១

កាលពីថ្ងៃអាទិត្យ សាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់សមាជិក ៤នាក់នៃចលនាបរិស្ថានមាតាធម្មជាតិ ពីបទរួមគំនិតក្បត់ប្រឆាំងនឹងរដ្ឋ និងបទប្រមាថចំពោះអង្គព្រះមហាក្សត្រ ដែលជាផ្នែកនៃការផ្តន្ទាទោសដោយការដាក់គោលដៅ និងមិនអាចទទួលយកបាន ពីសំណាក់អាជ្ញាធរ ទៅលើអ្នកការពារបរិស្ថាន និងសកម្មជនមូលដ្ឋានជួរមុខ ។ អាជ្ញាធរ គួរបញ្ឈប់ការចាប់យុវជនជាសកម្មជនរបស់យើងដាក់ពន្ធនាគារ និងគួរចាប់ផ្តើមស្តាប់មតិយោបល់របស់ពួកគេ ដែលស្ថិតនៅជួរមុខក្នុងការចងក្រងឯកសារពី ហានិភ័យដែលប្រទេសកម្ពុជាកំពុងប្រឈម ចំពោះការជញ្ជក់ផលប្រយោជន៍ពីធនធានធម្មជាតិ និងការបំផ្លិចបំផ្លាញបរិស្ថាន ។ សកម្មជនបរិស្ថានទាំងនេះ បានធ្វើការដោយមិនខ្លាចនឿយហត់ និងមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីការពារផលប្រយោជន៍រួមរបស់ជាតិ ។

យើងខ្ញុំ ជាសហគមន៍ និងសង្គមស៊ីវិល មានរាយនាមដូចខាងក្រោម សូមស្នើសុំឱ្យដោះលែង សកម្មជនបរិស្ថានដែលត្រូវបានចាប់ខ្លួនឱ្យបានឆាប់រហ័ស ទម្លាក់ចោលបទចោទទាំងអស់ប្រឆាំងពួកគេ និងបញ្ឈប់ការរឹតត្បិត និងការផ្តន្ទាទោសឥតឈប់ឈរទៅលើចលនាបរិស្ថាន ។

កញ្ញា ស៊ុន រដ្ឋា លោក យឹម លាងហ៊ី និងលោក Alejandro Gonzalez-Davidson ត្រូវបានចោទប្រកាន់ពីបទរួមគំនិតក្បត់ និងបទប្រមាថចំពោះអង្គព្រះមហាក្សត្រ តាមបញ្ញត្តិមាត្រា ៤៥៣ និងមាត្រា ៤៣៧ (ស្ទួន) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលមានទោសអតិបរមានីមួយៗរហូតដល់ ១០ឆ្នាំ និង៥ឆ្នាំ ។ សកម្មជនម្នាក់ទៀតគឺ លោក លី ចាន់ដារ៉ាវុត ត្រូវបានចោទប្រកាន់ពីបទរួមគំនិតក្បត់ ។

សកម្មជនទាំង៣នាក់ ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន នៅមណ្ឌលអប់រំកែប្រែទី១ (ម១) និងមណ្ឌលអប់រំកែប្រែទី២ (ម២) នៅក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ នេះ ខណៈដែលលោក Alejandro Gonzalez-Davidson កំពុងស្ថិតនៅក្រៅប្រទេសកម្ពុជា បន្ទាប់ពីលោកត្រូវបានបណ្តេញចេញកាលពីឆ្នាំ២០១៥ ។

កញ្ញា រដ្ឋា និងលោក ចាន់ដារ៉ាវុត ត្រូវបានចាប់ខ្លួន នៅតាមមាត់ទន្លេក្នុងរាជធានីភ្នំពេញ រួមជាមួយលោក សិដ្ឋ ឈីវលីម៉េង ដែលក្រោយមកលោកត្រូវបានដោះលែងវិញ ។ ពេលនោះ អ្នកទាំង៣ កំពុងចងក្រងឯកសារពីការបង្ហូរទឹកស្អុយចូលទៅក្នុងទន្លេ ។ ក្នុងពេលនោះដែរ អាជ្ញាធរស្រុកកោះធំ ខេត្តកណ្តាល បានកោះហៅ លោក យឹម លាងហ៊ី សកម្មជនបរិស្ថាន ដើម្បីធ្វើការសាកសួរ និងចាប់ខ្លួនលោក ដោយក្រោយមក លោកត្រូវបានបញ្ជូន

មករាជធានីភ្នំពេញ ។ ទីតាំងរបស់អ្នកទាំង៤ ត្រូវបានលាក់ការសម្ងាត់អស់រយៈពេលយ៉ាងតិច ២៤ម៉ោង បន្ទាប់ពីការចាប់ខ្លួនពួកគេ ដែលបានធ្វើឱ្យប៉ះពាល់ផ្លូវចិត្តក្រុមគ្រួសាររបស់ពួកគេយ៉ាងខ្លាំង ក៏ដូចជាដកហូតសិទ្ធិរបស់ពួកគេក្នុងការទទួលបានការប្រឹក្សាផ្លូវច្បាប់ក្នុងពេលចាប់ខ្លួន ។

ក្រោយមក សកម្មជនបរិស្ថានទាំង៣នាក់ ត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងរាជធានីភ្នំពេញ និងសាកសួរដោយព្រះរាជអាជ្ញា នៅថ្ងៃទី១៩ និងត្រូវបានចោទប្រកាន់នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ ពី បទរួមគំនិតក្បត់ និងបទប្រមាថចំពោះអង្គព្រះមហាក្សត្រ ដែលត្រូវបានទម្លាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយគាំទ្ររដ្ឋាភិបាល មុនពេលមេធាវីអ្នកទាំងនោះទទួលបានព័ត៌មានពីបទចោទទាំងនេះ ។ សកម្មភាពនេះ បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់សកម្មជនបរិស្ថានទាំងនេះ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

លោក លាងហ៊ី អាយុ ៣២ ឆ្នាំ គឺជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈកម្មវិធីអាហារូបករណ៍ ។ កញ្ញា រដ្ឋា អាយុ ២៦ ឆ្នាំ គឺជាគណនេយ្យករ ដែលទើបបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យកម្ពុជា ដែលកញ្ញាបានសិក្សាតាមរយៈកម្មវិធីអាហារូបករណ៍ផងដែរ ។ លោក ចាន់ដារ៉ាវុត អាយុ ២២ ឆ្នាំ គឺជានិស្សិតឆ្នាំទី៤ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ការចាប់ខ្លួនពួកគេគឺមិនសមហេតុផល និងបទចោទប្រឆាំងពួកគេគឺគ្មានមូលដ្ឋានច្បាស់លាស់ និងជាឧទាហរណ៍មួយទៀតនៃអាជ្ញាធរកម្ពុជា និងប្រព័ន្ធយុត្តិធម៌ ក្នុងការប្រើប្រាស់បទចោទមិនត្រឹមត្រូវ ដើម្បីចាប់អ្នកការពារសិទ្ធិមនុស្សវ័យក្មេង ដាក់ពន្ធនាគារ ។ ការតស៊ូមតិសម្រាប់សិទ្ធិមនុស្ស និងការទាមទារឱ្យអាជ្ញាធរការពារបរិស្ថាន មិនមែនជាបទល្មើសនោះទេ ហើយការចាប់ខ្លួនអ្នកការពារបរិស្ថានដែលជាយុវជនជំនាន់ក្រោយរបស់ប្រទេសជាតិ ដាក់ពន្ធនាគារ គឺធ្វើឱ្យមានគ្រោះថ្នាក់ដល់យើងទាំងអស់គ្នា ។

ការចាប់ខ្លួននេះ កើតឡើងតិចជាង ២ខែ បន្ទាប់ពីសកម្មជនមាតាធម្មជាតិចំនួន ៣នាក់ ត្រូវបានផ្តន្ទាទោសកាលពីខែឧសភា ឆ្នាំ២០២១ ពាក់ព័ន្ធនឹងបទញុះញង់ដែលគ្មានមូលដ្ឋានច្បាស់លាស់ ។ លោក ថុន រដ្ឋា កញ្ញា ភួន កែវរស្មី និងកញ្ញា ឡុង គន្ធា ត្រូវបានផ្តន្ទាទោស និងដាក់ទោសឱ្យជាប់ពន្ធនាគារចន្លោះពី ១៨ខែ ទៅ ២០ខែ ពាក់ព័ន្ធនឹងគម្រោងរៀបចំការដើរតវ៉ាដោយស្ត្រីម្នាក់ នៅក្នុងរាជធានីភ្នំពេញ ដើម្បីតស៊ូមតិប្រឆាំងនឹងការលុបបឹងតាមោក ដែលត្រូវបានបែងចែកជាចំណែកតូចៗសម្រាប់ផលប្រយោជន៍បុគ្គលឯកជន និងស្ថាប័នរដ្ឋ ។ លោក Alejandro Gonzalez-Davidson និងសកម្មជនម្នាក់ទៀត គឺកញ្ញា ជា គន្ធីន ត្រូវបានផ្តន្ទាទោស ដោយកំបាំងមុខ ។

ក្នុងឆ្នាំ២០២០ អាជ្ញាធរបានចាប់ខ្លួន សកម្មជនជាយុវជនយ៉ាងតិច ១៦នាក់ ដោយសារការតវ៉ាប្រឆាំងនឹងការឃុំខ្លួន លោក រ៉ុង ឈុន ប្រធានសហជីព ដែលត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទញុះញង់ ជុំវិញសេចក្តីអធិប្បាយរបស់លោកអំពីបញ្ហាព្រំដែនប្រទេសកម្ពុជា និងវៀតណាម ។

ខណៈដែលពន្ធនាគារមានសភាពចង្អៀតណែនខ្លាំងនៅទូទាំងប្រទេស កំពុងជួបការលំបាកចំពោះការផ្ទុះឡើងនៃការរីករាលដាលជំងឺកូវីដ១៩ សាធារណជនអាចយល់ថា អាជ្ញាធរហាក់ដូចជាមានចេតនាក្នុងការចាប់ខ្លួនអ្នកណាដែលបញ្ចេញមតិរិះគន់ ឬតវ៉ាដោយសន្តិវិធី ។ តុលាការ បានបង្ហាញចេតនាតិចតួចក្នុងការដោះលែងមុនពេលកំណត់ចំពោះពិរុទ្ធជន ដែលបានប្រព្រឹត្តបទល្មើសអហិង្សា ឬដោះលែងអ្នកទាំងនោះឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ប៉ុន្តែផ្ទុយទៅវិញ នៅតែបន្តចាប់ខ្លួនសកម្មជនអហិង្សាដាក់ពន្ធនាគារ ដោយឱ្យពួកគេប្រឈមនឹងហានិភ័យចំពោះបញ្ហាសុខភាព ។

យើងខ្ញុំ សូមស្នើសុំឱ្យដោះលែងសកម្មជនបរិស្ថាននៃចលនាមាតាធម្មជាតិទាំងនេះ ក៏ដូចជាសកម្មជនការពារបរិស្ថាន និងសកម្មជនសិទ្ធិមនុស្សដទៃទៀតដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ ឱ្យបានឆាប់រហ័ស ព្រមទាំងទម្លាក់ចោលបទចោទទាំងអស់ចំពោះអ្នកទាំងនោះដោយគ្មានលក្ខខណ្ឌ ៕

**សេចក្តីថ្លែងការណ៍នេះ គាំទ្រដោយ៖**

1. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
2. សហគមន៍អមលាំង (កំពង់ស្ពឺ)
3. សម្ព័ន្ធគណនេយ្យភាពសង្គម កម្ពុជា (ANSA)
4. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
5. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
6. សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ (AEC)
7. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
8. សម្ព័ន្ធសហជីពកម្ពុជា (CATU)
9. សហភាពការងារកម្ពុជា (CLC)
10. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
11. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
12. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
13. សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា (CDPLA)
14. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
15. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
16. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA-CLC)
17. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
18. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
19. បណ្តាញយុវជនកម្ពុជា (CYN)

20. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
21. សហគមន៍ដីធ្លីចក្រី (បន្ទាយមានជ័យ)
22. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
23. សហគមន៍ដីធ្លីជីខលើ (កោះកុង)
24. សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ (រតនគិរី)
25. សហគមន៍ជាំក្រវៀន (ត្បូងឃ្មុំ)
26. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
27. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
28. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
29. បណ្ដាញកសាងសន្តិភាពសហគមន៍ (CPN)
30. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
31. សហគមន៍ដកពរ (កំពង់ស្ពឺ)
32. អង្គការសមធម៌កម្ពុជា (EC)
33. សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
34. សហជីពកម្មករនិយោជិតក្រុមហ៊ុន អេច.ស៊ី.ស៊ី.គ្រុប
35. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
36. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
37. សហគមន៍ជនជាតិដើមភាគតិចឃុំប្រមេរុខេត្តព្រះវិហារ
38. សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)
39. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
40. សហគមន៍នេសាទកោះស្រឡៅ (កោះកុង)
41. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើល
42. សហគមន៍ដីធ្លីខេត្តប៉ៃលិន
43. សហគមន៍ឡពាង (កំពង់ឆ្នាំង)
44. សហគមន៍មានជ័យ (ស្វាយរៀង)
45. អង្គការម្លប់តាប៉ាង
46. មាតាធម្មជាតិកម្ពុជា (MNC)
47. សហគមន៍អូរដំដែក (កំពង់ធំ)
48. សហគមន៍អូរល្ហីព្រេង (បាត់ដំបង)
49. អង្គការស្ពានសន្តិភាព (PBO)
50. សហគមន៍ពាមរស់ (កំពង់ស្ពឺ)

51. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)
52. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
53. សហគមន៍ដីធ្លីភូមិផ្សារកណ្ដាល (បន្ទាយមានជ័យ)
54. សហគមន៍ភ្នំក្រោម (សៀមរាប)
55. អង្គការពន្លកខ្មែរ (PKH)
56. សហគមន៍ដីធ្លីព្រៃពាយ (កំពត)
57. សហគមន៍ព្រៃឈើពេជ្រចង្វារល្អឆើត (កំពង់ឆ្នាំង)
58. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
59. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
60. អង្គការគាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា (RCTSO)
61. អង្គការសមាគមធាងត្នោត (សធត)
62. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
63. សហគមន៍សាមគ្គីរមាសហែក (ស្វាយរៀង)
64. សហជីពកម្មករនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុនអេចស៊ីស៊ី ព្រលានយន្តហោះខេត្តសៀមរាប
65. សហជីពសាមគ្គីឯករាជ្យនៃសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រាភ្នំពេញ
66. សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
67. សហគមន៍ដីធ្លីតានី (សៀមរាប)
68. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើង លើស្ត្រីភេទ (NGO-CEDAW)
69. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
70. អង្គការតម្លាភាពកម្ពុជា (TI)
71. សហជីពនិយោជិតវិស័យទេសចរណ៍នៃអឺផាតម៉ិនឡេហ្សាដាំងឧយបាសាក់
72. សហជីពកម្មករនិយោជិតវិស័យទេចរណ៍នៃស៊ីនទ្រី(ខេមបូឌា)
73. សហជីពកម្មករនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុនជីអេសអាយ
74. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
75. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)